**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំខែកក្កដា ឆ្នាំ២០២១ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងខែកក្កដានេះ ការងារបង្កបង្កើនផលដំណាំរដូវវស្សាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ជាពិសេសស្រូវរដូវវស្សាសម្រេចបាន ២ ៤៤៦ ២៨៦ហ.ត ស្មើនឹង៩៣,៧៦% នៃផែនការចំនួន ២ ៦០៩ ០៦៥ហ.ត។ វិធានការជំរុញផលិតកម្មដំណាំ ការចិញ្ចឹមសត្វ និងវារីវប្បកម្មត្រូវបានដាក់ចេញ និងអនុវត្តយ៉ាងសកម្មដើម្បីជួយដល់កសិករ។ រីឯការចូលរួមទប់ស្កាត់បទល្មើស ជាពិសេសបទល្មើសព្រៃឈើ បទល្មើសជលផល បទល្មើសចលនាសត្វដោយខុសច្បាប់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងខែកក្កដានេះ គឺបានរៀបចំកិច្ចប្រជុំការងារចាំបាច់តាមរយៈការប្រជុំពីចម្ងាយ រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។ ចំពោះលទ្ធផល និងសកម្មភាពការងារតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំ២០២១ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានគិតត្រឹមខែកក្កដា ឆ្នាំ២០២១នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែកដាំដុះ

### ១.១ ផលិតកម្មដំណាំស្រូវរដូវវស្សា

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ២ ៥៤៤ ១៥១ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ១៥ ៨៤២ហ.ត ស្មើនឹង០,៦២% និងដោយគ្រឿងយន្តចំនួន ២ ៥២៨ ៣០៩ហ.ត ស្មើនឹង៩៩,៣៨%
- ផ្ទៃដីសាបសម្រេចបានចំនួន ១១ ៩៥៥ហ.ត តិចជាងឆ្នាំមុនចំនួន ១ ០៤៦ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ២ ៤៤៦ ២៨៦ហ.ត ស្មើនឹង៩៣,៧៦% នៃផែនការចំនួន ២ ៦០៩ ០៦៥ហ.ត លើសឆ្នាំមុន ១៦៤ ៣៦៥ហ.ត។

### ១.២ ការប្រមូលផលស្រូវស្រាលរដូវវស្សា

ការប្រមូលផលស្រូវស្រាលសម្រេចបានចំនួន ១២១ ៩៥៣ហ.ត ដោយទទួលបរិមាណផលសរុបចំនួន ៤៩៨ ២៩៩តោន លើសឆ្នាំមុនចំនួន ២៣០ ៦០៣តោន និងទទួលបានទិន្នផលគិតជាមធ្យម ៤,០៨៦តោន/ហ.ត។

### ១.៣ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្មរដូវវស្សា

-ដំណាំសាកវប្បកម្មអនុវត្តបានសរុបចំនួន ៤៨ ២៨៧ហ.ត ស្មើនឹង៨៩,៩៤% នៃផែនការចំនួន ៥៣ ៦៨៦ហ.ត តិចជាងឆ្នាំមុន ១ ២៣៧ហ.ត

-ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៧៣១ ៤៩០ហ.ត ស្មើនឹង៨៩,២១% នៃផែនការចំនួន ៨១៩ ៩៨៩ហ.ត តិចជាងឆ្នាំមុន ៨៩៩ហ.ត។

### ១.៤ ការនាំចេញផលិតផលកសិកម្ម

#### ១.៤.១ ការនាំចេញអង្ករ

- ការនាំចេញអង្ករក្នុងខែកក្កដា ឆ្នាំ២០២១ មានចំនួន ២៩ ៤១៥តោន កើនឡើងចំនួន ១ ០០២តោន (៣,៥៣%) បើធៀបខែកក្កដា ឆ្នាំ២០២០ ដែលមានចំនួន ២៨ ៤១៣តោន

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣ ២១៧ ៣២០
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

- បរិមាណអង្ករនាំចេញក្នុងរយៈពេល៧ខែឆ្នាំ២០២១ មានចំនួន ៣០៩ ៨៦៥តោន មានការថយចុះចំនួន ១១៦ ២០៨តោន (-២៧,២៧%) បើធៀបបរិមាណនាំចេញក្នុងរយៈពេល៧ខែឆ្នាំ២០២០ ដែលមានចំនួន ៤២៦ ០៧៣តោន

- ក្នុងរយៈពេល៧ខែឆ្នាំ២០២១ អង្ករបាននាំចេញទៅកាន់ទិសដៅសហភាពអឺរ៉ុបចំនួន ២១ប្រទេស មានបរិមាណសរុបចំនួន ៧៧ ៨៦៦តោន (ថយចុះចំនួន ៦៦ ៤៦១តោន ស្មើនឹង -៤៦,០៧%) ទិសដៅប្រទេសចិនមានបរិមាណសរុបចំនួន ១៥៣ ៩២១តោន (ថយចុះចំនួន ១ ៤០៦តោន ស្មើនឹង -០,៩១%) ទិសដៅអាស៊ានចំនួន ៥ប្រទេស មានបរិមាណសរុបចំនួន ២៩ ៤៥៣តោន(ថយចុះចំនួន ២៧ ៦១១តោន ស្មើនឹង -៤៨,៣៩%) និងទិសដៅដទៃទៀតចំនួន២២ប្រទេស មានបរិមាណសរុប ៤៨ ៧០៥តោន (ថយចុះចំនួន ២០ ៧៣០តោន ស្មើនឹង -២៩,៨៦%)

- ក្រុមហ៊ុននាំចេញអង្ករមានចំនួន ៥៨ក្រុមហ៊ុន ហើយបរិមាណអង្ករដែលបាននាំចេញដោយក្រុមហ៊ុនធំៗចំនួន ១០ មានរហូតដល់ ២២៤ ៩៥២តោន (៧២,៦០%) និងក្រុមហ៊ុន ៤៨ដទៃទៀតបាននាំចេញត្រឹមតែ ៨៤ ៩១៣តោន (២៧,៤០%)។

**១.៤.២ ការនាំចេញស្រូវ**

ក្នុងរយៈពេល៧ខែ ឆ្នាំ២០២១ ការនាំចេញស្រូវមានចំនួន ២ ០០៨ ២៤១តោន ទៅកាន់ប្រទេសវៀតណាម និងប្រទេសអារ៉ាប់រួម (មានវិញ្ញាបនបត្រភូតគាមអនាម័យចំនួន ១ ២៩០ ៥០២,៥២តោន) ដែលមានការកើនឡើងចំនួន ៩០០ ៧៦៦តោន (៨១,៣៤%) បើធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០២០ ដែលមានចំនួន ១ ១០៧ ៤៧៥តោន។

**១.៤.៣ ការនាំចេញកសិផលផ្សេងៗ**

ក្នុងរយៈពេល៧ខែ ឆ្នាំ២០២១ មានបរិមាណនាំចេញ ដោយធៀបនឹងរយៈពេល៧ខែ ឆ្នាំ២០២០៖

- ដំឡូងមីស្រស់ចំនួន ៣៩៦ ៣០០តោន (ថយចុះចំនួន -៨,៦៤%) នាំចេញទៅប្រទេសថៃចំនួន ៩១ ២៥០តោន និងប្រទេសវៀតណាមចំនួន ៣០៥ ០៥០តោន

- ម្សៅដំឡូងមីចំនួន ១៨ ៤៦៥,០៤តោន (កើនឡើងចំនួន ២២,៤៣%) នាំចេញទៅប្រទេសចិនចំនួន ១៦ ៣៥៨,៦តោន ប្រទេសអ៊ីតាលីចំនួន ៣៤០,៦៤តោន ប្រទេសណេដឺឡែនចំនួន ១៥២តោន ប្រទេសថៃចំនួន ១ ៣៧៥,៨តោន សហរដ្ឋ-អាមេរិកចំនួន ១៧០តោន និងប្រទេសប៊ែលហ្ស៊ិកចំនួន ៦៨តោន

- គ្រាប់ស្វាយចន្ទីមានចំនួន ៨៦៦ ២០៧,៧៧តោន (កើនឡើងចំនួន ៣៤៥,២៩%) នាំចេញទៅប្រទេសចិនចំនួន ៣ ៦៣៩,៥តោន ប្រទេសឥណ្ឌាចំនួន ១៧តោន ប្រទេសជប៉ុនចំនួន ៣៤,៤៣តោន ប្រទេសកូរ៉េចំនួន ៣,៩១តោន ប្រទេសឡាវចំនួន ២តោន ប្រទេសអារ៉ាប់រួមចំនួន ១៤,៥១តោន ប្រទេសតូហ្គោចំនួន ០,០១តោន ប្រទេសថៃចំនួន ៣ ១៩៩,៤០តោន ប្រទេសអារ៉ាប់រួមចំនួន ០,០១តោន ប្រទេសវៀតណាមចំនួន ៨៥៩ ២៩០តោន និងប្រទេសបង់ក្លាដែសចំនួន ៧តោន

- គ្រាប់ពោតមានចំនួន ១៤៦ ៣០៤,១៩តោន (កើនឡើងចំនួន ១,០៩%) នាំចេញទៅប្រទេសបង់ក្លាដែសចំនួន ៤២តោន ប្រទេសកូរ៉េចំនួន ២១តោន កោះតៃវ៉ាន់ចំនួន ៧៥១,១៩តោន ប្រទេសថៃចំនួន ៤២ ៣៥០តោន និងប្រទេសវៀតណាមចំនួន ១០៣ ១៤០តោន

- គ្រាប់សណ្តែកបាយមានចំនួន ២១ ២៣០តោន (កើនឡើងចំនួន ៥៤៧,៣៣%) នាំចេញទៅប្រទេសវៀតណាម

- គ្រាប់សណ្តែកសៀងមានចំនួន ១៩ ៨៨០,០៤តោន (កើនឡើងចំនួន ១០០%) នាំចេញទៅប្រទេសថៃចំនួន ៧ ៩៥០តោន ប្រទេសអារ៉ាប់រួមចំនួន ០,០៤តោន និងប្រទេសវៀតណាមចំនួន ១១ ៩៣០តោន

- ផ្លែចេកស្រស់មានចំនួន ២៧០ ២២១,៦៨តោន (កើនឡើងចំនួន ៦១,០៨%) នាំចេញទៅប្រទេសចិនចំនួន ២៤០ ១០៨,៥៧តោន ប្រទេសជប៉ុនចំនួន ៤៩៥,៣០តោន ប្រទេសសិង្ហបុរីចំនួន ៤៨០,៤៨តោន និងប្រទេសវៀតណាមចំនួន ២៩ ១៣៧,៣៣តោន

- ផ្លែក្រូចថ្លុងមានចំនួន ២៧ ៤១៨,៤៤តោន (កើនឡើងចំនួន ៩០,៤១%) នាំចេញទៅប្រទេសថៃចំនួន ២៧ ៣៥៤តោន និងប្រទេសវៀតណាមចំនួន ៦៤,៤៤តោន

- ផ្លែស្វាយស្រស់មានចំនួន ១៦១ ២២៨,៥៥តោន (កើនឡើងចំនួន ២៤៧,៩២%) នាំចេញទៅទីក្រុងហុងកុងចំនួន ៥០,៧៨តោន ប្រទេសកូរ៉េចំនួន ១២៤,៣៨តោន ប្រទេសគុយវ៉ែតចំនួន ០,០១តោន ប្រទេសសិង្ហបុរីចំនួន ១៦,២០តោន ប្រទេសថៃចំនួន ២១ ២១៩,២៨តោន ប្រទេសវៀតណាមចំនួន ១៣៩ ៦០៦,៦៨តោន និងប្រទេសចិនចំនួន ២១១,២២តោន

- ដូងប្រេងមានចំនួន ២៩ ៦១៦,៦៩តោន (ថយចុះចំនួន -៩,៧៣%) នាំចេញទៅប្រទេសឥណ្ឌាចំនួន ២៤ ២១៦,៦៩តោន និងប្រទេសម៉ាឡេស៊ីចំនួន ៥ ៤០០តោន

- ម្រេចមានចំនួន ២២ ៥៨០,៦៨តោន (កើនឡើងចំនួន ៥៥៨,១៩%) នាំចេញទៅប្រទេសប៊ែលហ្ស៊ិកចំនួន ១៥,៩៨តោន ប្រទេសកាណាដាចំនួន ០,៥២តោន សាធារណរដ្ឋឆែកចំនួន ៦,១០តោន ប្រទេសបារាំងចំនួន ២០,១៤តោន ប្រទេសអាល្លឺម៉ង់ចំនួន ២៤៤,៥៧តោន ប្រទេសឥណ្ឌាចំនួន ៤២តោន ប្រទេសជប៉ុនចំនួន ២,៥៨តោន ប្រទេសកូរ៉េចំនួន

១,៥៥តោន ប្រទេសប៉ូឡូញចំនួន ៧,០៩តោន ប្រទេសរុស្សីចំនួន ០,៨០តោន ប្រទេសស៊ុយអ៊ែត ចំនួន ១,២៩តោន ប្រទេសស្វីសចំនួន ០,៤៨តោន កោះតៃវ៉ាន់ចំនួន ១៥តោន ប្រទេសអង់គ្លេសចំនួន ១,២៤តោន ប្រទេសអារ៉ាប់រួមចំនួន ០,០១តោន សហរដ្ឋអាមេរិកចំនួន ១,៧៥តោន ប្រទេសវៀតណាមចំនួន ២២ ២១៧,៤២តោន ប្រទេសសិង្ហបុរីចំនួន ១,៩៧តោន និងប្រទេសកាហ្សាក់ស្ថានចំនួន ០,១៩តោន

- ម្ទេសស្រស់មានចំនួន ៦៦ ២២៧,១២តោន (កើនឡើងចំនួន ៤៦%) ទៅប្រទេសថៃចំនួន ៦៦ ២២៧,១២តោន និងប្រទេសអារ៉ាប់រួមចំនួន ០,០០២តោន

- ម្ទេសក្រៀមមានចំនួន ១ ៣២០,២២តោន (កើនឡើងចំនួន ១០,០២%) ទៅប្រទេសថៃចំនួន ១ ៣២០តោន ប្រទេសប៊ែលហ្ស៊ិកចំនួន ០,២១តោន និងប្រទេសកាណាដាចំនួន ០,០១តោន។

## ២ ផ្នែកផលិតកម្មកៅស៊ូ (ខែមិថុនា)

### ២.១ ផ្ទៃដីកៅស៊ូ

- ផ្ទៃដីកៅស៊ូសរុបចំនួន ៤០៤ ១៦០ហ.ត ក្នុងនោះ ផ្ទៃដីចម្ការកៅស៊ូកសិ-ឧស្សាហកម្មចំនួន ៤៨ ៥៤៦ហ.ត ផ្ទៃដីចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ចចំនួន ១៩៤ ៤៥៤ហ.ត និងផ្ទៃដីចម្ការកៅស៊ូគ្រួសារចំនួន ១៦១ ១៦០ហ.ត។ ផ្ទៃដីចៀរជ័រចំនួន ២៩២ ៥១៩ហ.ត ស្មើនឹង៧២% និងផ្ទៃដីថែទាំចំនួន ១១១ ៦៤១ហ.ត ស្មើនឹង២៨%។

### ២.២ ផលិតកម្មកៅស៊ូ

- ផលិតផលជ័រកៅស៊ូចំនួន ៣០ ៧២៥តោន កើនឡើងចំនួន ៤ ៦៧៧តោន ស្មើនឹង១៧,៩៦% ធៀបខែមុន និងកើនឡើងចំនួន ២ ៥៦២តោន ស្មើនឹង៩,១០% ធៀបខែមិថុនា ឆ្នាំ២០២០

- ផលិតផលឈើកៅស៊ូចំនួន ៤៨៥ម³ កើនឡើងចំនួន ១៨៩ម³ ស្មើនឹង៦៣,៨៥% ធៀបខែមុន។

### ២.៣ ការនាំចេញកៅស៊ូ

- បរិមាណជ័រកៅស៊ូបញ្ចេញលក់ចំនួន ២៨ ៩៣១តោន កើនឡើងចំនួន ៣ ៦២៨តោន ស្មើនឹង១៤,៣៤% ធៀបខែមុន និងកើនឡើងចំនួន ២ ៩១១តោន ស្មើនឹង១១,១៩% ធៀបខែមិថុនា ឆ្នាំ២០២០

- បរិមាណបញ្ចេញលក់ឈើកៅស៊ូចំនួន ៤៨៥ម³ កើនឡើងចំនួន ១៨៩ម³ ស្មើនឹង៦៣,៨៥% ធៀបខែមុន។

### ២.៤ តម្លៃកៅស៊ូ

- តម្លៃជ័រកៅស៊ូលក់មធ្យមក្នុងខែមិថុនាគឺ១ ៧៣៥ដុល្លារ/តោន កើនឡើងចំនួន ៣៥ដុល្លារ/តោន ស្មើនឹង២,០៤% ធៀបខែមុន និងកើនឡើងចំនួន ៤៦៨ដុល្លារ/តោន ស្មើនឹង៣៦,៩៤% ធៀបខែមិថុនា ឆ្នាំ២០២០

- តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារចម្ការក្នុងខែមិថុនាគឺទឹកជ័រ (DRC ១០០%) មានការប្រែប្រួលពី ៥ ៨៥០៛/គ.ក្រ ដល់ ៦ ៥០០៛/គ.ក្រ និងជ័រកក (DRC50%) មានការប្រែប្រួលពី ២ ៥០០៛/គ.ក្រ ដល់ ៣ ៣០០៛/គ.ក្រ។

## ៣ ផ្នែកព្រៃឈើ

### ៣.១ ការងារព្រៃឈើ

- បាននិងកំពុងពិនិត្យ ផ្ទៀងផ្ទាត់ និងវាយតម្លៃគម្របព្រៃឈើឆ្នាំ២០២១

- ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន ១ក្រុមហ៊ុន និងអ្នកស្នើសុំចំនួន ២នាក់ មានឈើហ៊ុបមូលចំនួន ១ ២៦១ម³ កូនឈើចំនួន ៨ ១០៥ដើម អុសចំនួន ១៤៦ស្ទែរ និងជ័រទឹកចំនួន ៨០តោន

- ធ្វើសារពើភណ្ឌវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើជូនក្រុមហ៊ុន សាន ហ៊ាង (កម្ពុជា) អាហារ័ណ នីហារ័ណ ឯ.ក ខេត្តឧត្តរមានជ័យ។

### ៣.២ ការងារអភិរក្សសត្វព្រៃ

- សិក្សា និងអង្កេតសត្វព្រៃផ្ទាល់កំពុងរស់នៅ និងបន្តពូជនៅក្នុងសហគមន៍ព្រៃឈើវាលកន្សែងស្ថិតក្នុងស្រុកឆ្លូង ខេត្តក្រចេះ

- សហការជាមួយមន្ត្រីរដ្ឋបាលជលផលខេត្តស្ទឹងត្រែងដើម្បីចុះពិនិត្យពីស្ថានភាព និងការងារអភិរក្សសត្វកន្ធាយក្បាលកង្កែបតាមដងទន្លេមេគង្គក្នុងខេត្តស្ទឹងត្រែង និងខេត្តក្រចេះ និងពិនិត្យពីស្ថានភាពជាក់ស្តែង និងការងារអភិរក្សសត្វអណ្តើកហ្លួង និងសត្វក្រពើភ្នំក្នុងតំបន់ពងកូនតាមដងព្រែកស្រែអំបិលក្នុងខេត្តកោះកុង

- ចេញលិខិតអនុញ្ញាតដឹកជញ្ជូនសត្វព្រៃឆ្លោះទៅកាន់មាត់ច្រកអន្តរជាតិសម្រាប់នាំចេញចំនួន ៤ច្បាប់ មានសត្វស្វាក្ដាមសរុបចំនួន ១ ៨១៥ក្បាល និងលិខិតអនុញ្ញាតថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសារចំនួន ២២ច្បាប់ សម្រាប់ការថែរក្សាសត្វក្រចៀកកាំមានទីតាំងនៅខេត្តបន្ទាយមានជ័យ។

### ៣.៣ កសិដ្ឋានចិញ្ចឹម បង្កាត់ពូជសត្វស្វាក្ដាម និងការសង្គ្រោះសត្វព្រៃ

- ក្រុមហ៊ុនចំនួន៧កំពុងដំណើរការកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្ដាមយកកូននាំចេញមានទីតាំងស្ថិតនៅក្នុងរាជធានីភ្នំពេញ ខេត្តកំពង់ធំ សៀមរាប កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង មានស្វាក្ដាមចំនួន ៨៩ ៣៣៥ក្បាល ក្នុងនោះកូនកើតក្នុងខែចំនួន ៥ ៩០១ក្បាល

- នៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅមានសត្វព្រៃសរុបចំនួន ១ ៥៧៨ក្បាល(បក្សីចំនួន ៥៨ប្រភេទ ថនិកសត្វចំនួន ៤៥ប្រភេទ និងល្មូនចំនួន ១៦ប្រភេទ) សង្គ្រោះសត្វព្រៃថ្មីចំនួន ១០១ក្បាល ព្យាបាលចំនួន ២៩ក្បាល និងស្ដារលទ្ធភាពជីវសាស្ត្រសត្វព្រៃ និងដោះលែងសត្វព្រៃគ្រប់ប្រភេទទៅព្រៃធម្មជាតិចំនួន ១៥៣ក្បាល

- ក្រុមល្បាតសហគមន៍ចំនួន ៣០នាក់ ដើរល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន ៥គឺៈ អារ៉ែង ឆាយរាប តំបន់ស្ដារក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)

- ជួសជុលផ្លូវដោយក្រាលក្រួសក្រហមសរុបប្រវែង ៥០០ម៉ែត្រ និងកាប់ឆ្ការអនាម័យព្រៃទំហំ៥ហ.ត នៅក្នុងតំបន់សួនសត្វ។

### ៣.៤ ការងារដាំដើមឈើ

- ជីកប្រឡាយការពារចម្ការគ្រញូងនៅស្ថានីយផ្សព្វផ្សាយនិងស្ដារព្រៃឈើអន្លង់ថ្មខេត្តកំពង់ធំប្រវែង ៥០០ម៉ែត្រ

- ចុះបញ្ជីដីស្ថានីយផ្សព្វផ្សាយនិងស្ដារព្រៃឈើសំបួរមាសមានផ្ទៃដីទំហំ ២៦៦ ០៤៣ម៉ែត្រការ៉េ ស្ថិតក្នុងស្រុកបាណន់ ខេត្តបាត់ដំបង

- បាននិងកំពុងថែទាំចម្ការឈើសរុបទំហំ ៨២២ហ.ត ក្នុងនោះចម្ការពូជឈើទំហំ ៩៤ហ.ត ឡូតិ៍បង្ហាញកសិ-រុក្ខកម្មទំហំ ៤៤ហ.ត ចម្ការឈើដាំទំហំ ៦៥៤ហ.ត និងចម្ការរុក្ខទិវា ៩ កក្កដា ទំហំ៣០ហ.ត ស្ថិតក្នុងខេត្តកំពត កណ្ដាល សៀមរាប ព្រះសីហនុ ស្វាយរៀង កំពង់ធំ និងខេត្តក្រចេះ

- ដាំកូនឈើជាចម្ការពូជប្រភេទឈើ ធ្នង់ គ្រញូង និងកកោះទំហំ៤ហ.ត នៅក្នុងស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើអន្លង់ថ្មខេត្តកំពង់ធំ។

### ៣.៥ ការងារនីតិកម្ម និងវិវាទ

- សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃទទួលបានពីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងក្រុមអន្តរាគមន៍បង្ក្រាបបទល្មើសសត្វព្រៃចល័តនៃរដ្ឋបាលព្រៃឈើចំនួន ៩៥ករណី

- វត្ថុតាងនៃបទល្មើសព្រៃឈើដែលចាប់ឃាត់ និងដកហូតមាន ឈើអារចំនួន ៧៦ម³ ផ្ទៃដីព្រៃឈើបានកាប់រានទំហំ ៦៣៤ហ.ត និងអនុផលព្រៃឈើ ព្រមទាំងសម្ភារមួយចំនួនទៀត។

### ៣.៦ ការងារឧស្សាហកម្ម និងពាណិជ្ជកម្ម

- បានចុះពិនិត្យសំណើសុំពន្យារសុពលភាពរោងម៉ាស៊ីនអារកែច្នៃឈើ និងរោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើចំនួន ០៤ កន្លែង ស្ថិតនៅរាជធានីភ្នំពេញ ខេត្តបាត់ដំបង ក្រចេះ និងខេត្តមណ្ឌលគិរី

- ក្រុមហ៊ុនចំនួន៤នាំចេញផលិតផលរានទេវតា ឈើកែច្នៃទៅក្រៅប្រទេសមានបរិមាណចំនួន ៣៦ម³ ជ័រទឹកចំនួន ៥០តោន និងចំណាំងកម្ទេចឈើប្រេងខ្យល់ចំនួន ២ ៦៤០តោន និងក្រុមហ៊ុនចំនួន២នាំចូលឈើកែច្នៃចំនួន ១៩៨ម³

- បានផ្ដល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលជូនក្រុមហ៊ុនចំនួន១មានឈើកែច្នៃចំនួន ៥១០ម³។

### ៣.៧ ការងារចំណូលព្រៃឈើ

- ប្រមូលចំណូលសរុប ៧៤៩ ៣៩៩ ៧៥១រៀល និង១៨៦ ៤៣៨,៣៣ដុល្លារ។

## ៤ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

**៤.១ ការងារផលិតកម្មសត្វៈ** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្ដុះបណ្ដាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្ដាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្ដារាជធានី-ខេត្តរៀងរាល់សប្ដាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្តៈ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើសួនដំណាំចំណីសត្វ ការផ្ដល់ពូជស្មៅដល់កសិករ និងភ្នាក់ងារសុខភាព

សត្វភូមិ និងចុះពិនិត្យនិងកែសម្រួលឡជីវឧស្ម័នដែលបានសាងសង់រួចហើយ ដែលមានបញ្ហាបច្ចេកទេសនៅតាមខេត្តគោលដៅ។

### ៤.២ ការងារសុខភាពសត្វ

- **លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖** បទល្មើសសត្វនិងផលិត-ផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យ និងបង្ក្រាបយ៉ាងសកម្មដោយក្រុមអន្តរគមន៍របស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន ៤៨ករណី។ រាជធានី-ខេត្តចំនួន ២៥បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ១៥ ៤៥៨លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។
- **ការងារផ្សព្វផ្សាយបច្ចេកទេស**
  ចុះណែនាំកសិករ និងអ្នកពាក់ព័ន្ធស្តីពីជំងឺឆ្លងសត្វនៅតាមបណ្តាខេត្តចំនួន២។
- **ការងារនីតិកម្ម និងវិវាទ**

- កំពុងប្រជុំពិភាក្សាផ្ទៃក្នុងនាយកដ្ឋានលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការធ្វើអាជីវកម្មពិឃាតសត្វ ទីកន្លែងកែច្នៃបឋមផលិតផលសត្វ និងសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីគំរូសំណុំលិខិតដោះស្រាយបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ
- ចុះពិនិត្យ និងតាមដានការអនុវត្តច្បាប់លើវិស័យសុខភាពសត្វ និងផលិតកម្មសត្វនៅតាមបណ្តាខេត្តចំនួន២។

### ៤.៣ ការងារស្រាវជ្រាវ

- **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ១០៣ក្បាល។
- **ការងារស្រាវជ្រាវសុខភាពសត្វ៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺ និងងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបចំនួន ២ ៤៦០វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី និងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) និងជំងឺដុំពកស្បែកគោ ក្របី (LSD)។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប

- ដាយត្រីអនុវត្តបញ្ចប់ត្រឹមចំនួន ១ ៣១០តោន ស្មើនឹង១១,៩១% នៃផែនការចំនួន ១១ ០០០តោន ប្រៀបធៀបខែកក្កដា ឆ្នាំ២០២០ ថយចុះចំនួន ១៩០តោន
- នេសាទគ្រួសារដែននេសាទបានចំនួន ២១ ២០០តោន សរុបរយៈពេល៧ខែចំនួន ១៥៣ ៤០០តោន ស្មើនឹង៥១,១៣% នៃផែនការចំនួន ៣០០ ០០០តោន ប្រៀបធៀបខែកក្កដា ឆ្នាំ២០២០ កើនឡើងចំនួន ១ ១០០តោន
- នេសាទគ្រួសារតាមវាលស្រែបានចំនួន ៣ ៣០០តោន សរុបរយៈពេល៧ខែចំនួន ២៥ ៣០០តោន ស្មើនឹង១៨,០៧% នៃផែនការចំនួន ១៤០ ០០០តោន ប្រៀបធៀបខែកក្កដា ឆ្នាំ២០២០ ថយចុះចំនួន ១៤ ៨០០តោន។

#### ៥.១.២ នេសាទសមុទ្រ

បានចំនួន ១០ ៥០០តោន សរុបរយៈពេល៧ខែចំនួន ៦៧ ៩០០តោន ស្មើនឹង៥២,២៣% នៃផែនការចំនួន ១៣០ ០០០តោន ប្រៀបធៀបខែកក្កដា ឆ្នាំ២០២០ កើនឡើងចំនួន ២០០តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គាបានចំនួន ៣ ០៧២តោន សរុបរយៈពេល៧ខែចំនួន ១៤៧ ៤១២តោន ស្មើនឹង៣០,៦៥% នៃផែនការចំនួន ៤៨១ ០០០តោន ប្រៀបធៀបខែកក្កដា ឆ្នាំ២០២០ ថយចុះចំនួន ៣៨ ៤៨៨តោន
- ការចិញ្ចឹមក្រពើបានចំនួន ៥០ ២០០ក្បាល សរុបរយៈពេល៧ខែចំនួន ១៤២ ៤០០ក្បាល ស្មើនឹង៤៣,១៥% នៃផែនការចំនួន ៣៣០ ០០០ក្បាល ប្រៀបធៀបខែកក្កដា ឆ្នាំ២០២០ ថយចុះចំនួន ៣៨ ៨៤០ក្បាល
- ការភ្ញាស់កូនត្រីពូជបានចំនួន ៣៨ ២០០ ០០០កូន សរុបរយៈពេល៧ខែចំនួន ១២២ ៥០០ ០០០កូន ស្មើនឹង៤៥,៣៧% នៃផែនការចំនួន ២៧០ ០០០ ០០០កូន ប្រៀបធៀបខែកក្កដា ឆ្នាំ២០២០ កើនឡើងចំនួនប្រមាណ ១ ០០០ ០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបបានចំនួន ៦ ០០០តោន សរុបរយៈពេល៧ខែចំនួន ៣១ ៩១០តោន ស្មើនឹង៣៩,៨៩% នៃផែនការចំនួន ៨០ ០០០តោន ប្រៀបធៀបខែកក្កដា ឆ្នាំ២០២០ ថយចុះចំនួន ១ ១៤០តោន

- ផលនេសាទសមុទ្របានចំនួន ៨៣០តោន សរុបរយៈពេល៧ខែចំនួន ៦ ៩៦០តោន ស្មើនឹង៥៨% នៃផែនការចំនួន ១២ ០០០តោន ប្រៀបធៀបខែកក្កដា ឆ្នាំ២០២០ កើនឡើងចំនួន ២០តោន

- ការផលិតទឹកត្រីបានចំនួន ២ ០០៨ ០០០លីត្រ សរុបរយៈពេល៧ខែចំនួន ៣៦ ៧៥៨ ០០០លីត្រ ស្មើនឹង ៦៦,៨៣% នៃផែនការចំនួន ៥៥ ០០០ ០០០លីត្រ ប្រៀបធៀបខែកក្កដា ឆ្នាំ២០២០ ថយចុះចំនួន ១ ៧៥៤ ០០០លីត្រ។

### ៥.៤ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផល

- សំណុំរឿងបទល្មើសជលផលមានចំនួន ២៨១ករណី ប្រៀបធៀបខែកក្កដា ឆ្នាំ២០២០ កើនឡើងចំនួន ១០៧ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ២៥៧ករណី និងសមុទ្រចំនួន ២៤ករណី។

### ៥.៥ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់នាំចេញចំនួន ៣១៤តោន សរុបរយៈពេល៧ខែចំនួន ២ ២៥៩តោន ស្មើនឹង២៨,២៤% នៃផែនការចំនួន ៨ ០០០តោន ប្រៀបធៀបខែកក្កដា ឆ្នាំ២០២០ កើនឡើងចំនួន ១ ១១៩តោន

- ផលនេសាទកែច្នៃនាំចេញចំនួន ៣តោន សរុបរយៈពេល៧ខែចំនួន ១៥០តោន ស្មើនឹង៧,៥០% នៃផែនការចំនួន ២ ០០០តោន ប្រៀបធៀបខែកក្កដា ឆ្នាំ២០២០ ថយចុះចំនួន ៨២តោន។

### ៥.៦ ការប្រមូលថវិកាសេវាជលផល

- សរុបចំណូលរយៈពេល៧ខែចំនួន ៤២៤ ៩២៦ ១២៨រៀល ស្មើនឹង១១៨,៥០% នៃផែនការចំនួន ៣៥៨ ៦០០ ០០០រៀល ប្រៀបធៀបខែកក្កដា ឆ្នាំ២០២០ កើនឡើងចំនួន ៣០ ៤៧២ ២៣២រៀល។

## ៦ ផ្នែកអធិការដ្ឋាន

- ការទទួលពាក្យបណ្តឹងតាមរយៈប្រអប់សំបុត្រ និងតាមរយៈប្រព័ន្ធអ៊ិនធើណេតចំនួន ២ករណី

- ស្រាវជ្រាវព័ត៌មានតាមបណ្តាគេហទំព័រពាក់ព័ន្ធនឹងវិស័យកសិកម្មចំនួន ៥៨ករណី លើវិស័យព្រៃឈើ១២ករណី ជលផល៨ករណី សុខភាពសត្វនិងផលិតកម្មសត្វ៨ករណី និងវិស័យផ្សេងៗ៣០ករណី។

## ៧ ផ្នែករដ្ឋបាល

- បានទទួលលិខិតសរុបចំនួន ៧៥៧ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានាចំនួន ២៩៣ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ៣១៨ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ១៤៦ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល

- បានបញ្ជូនឯកសារ និងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ១ ០៤៩ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរចំនួន ៤២ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ២១ច្បាប់

- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ

- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំដើម្បីក្តាប់ឱ្យបាននូវរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការក្នុងការទទួលគណៈប្រតិភូជាតិ-អន្តរជាតិ ការរៀបចំកិច្ចប្រជុំនិងពិធីបុណ្យផ្សេងៗ ការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ៖ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម)។

## ៨ ផ្នែកបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសចំនួន ៥ ៨២៣នាក់ (ស្រី១ ៤១៣នាក់ ស្មើនឹង២៤,២៦%) រួមមាន៖
  + អង្គភាពថ្នាក់កណ្តាលចំនួន ២ ៩១៤នាក់ (ស្រី៨២៣នាក់ ស្មើនឹង២៨,២៤%)
  + អង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ២ ៩០៩នាក់ (ស្រី៥៩០នាក់ ស្មើនឹង២០,២៨%)

- តែងតាំងដំឡើងឋានៈ និងផ្ទេរសម្រួលភារកិច្ចមន្ត្រីរាជការសរុបចំនួន ៧០នាក់ (ស្រី២៩នាក់)

- រៀបចំប្រកាសលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌចំនួន ៧នាក់ (ស្រី៣នាក់) ក្នុងនោះ ដោយសុំលាឈប់ពីការងារចំនួន ៤នាក់ និងមរណភាពចំនួន ៣នាក់

- រៀបចំប្រកាសផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួងចំនួន ៧នាក់ (ស្រី១នាក់) ផ្ទេរចូលក្នុងក្រសួងចំនួន ៤នាក់ និងផ្ទេរផ្ទៃក្នុងក្រសួងចំនួន ៣៩នាក់

- រៀបចំលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកការងារចំនួន ៣៣នាក់ (ស្រី២០នាក់) ក្នុងនោះ ច្បាប់ឈប់សម្រាកប្រចាំឆ្នាំចំនួន ៥នាក់ ច្បាប់ឈប់សម្រាករយៈពេលខ្លីចំនួន ៤នាក់ ច្បាប់ឈប់សម្រាកលំហែមាតុភាពចំនួន ១៦នាក់ និងច្បាប់ឈប់សម្រាកសម្រាប់ព្យាបាលជំងឺចំនួន ៨នាក់

- រៀបចំប្រកាសដាក់ឱ្យមន្ត្រីរាជការចូលនិវត្តន៍ចំនួន ១៥នាក់ (ស្រី៨នាក់)

- រៀបចំប្រកាសដាក់ឱ្យមន្ត្រីរាជការចូលបម្រើការងារវិញចំនួន ៧នាក់ (ស្រី១នាក់)

- រៀបចំប្រកាសដាក់ឱ្យមន្ត្រីរាជការស្ថិតក្នុងភាពទំនេរគ្មានបៀវត្សចំនួន ១៥នាក់ (ស្រី២នាក់)

- រៀបចំសំណើទៅក្រសួងមុខងារសាធារណៈស្តីពីសំណើសុំដំឡើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការប្រចាំឆ្នាំ២០២១ ចំនួន២ ៨៣៦នាក់ (ស្រី៦៤២នាក់) ក្នុងនោះ ថ្នាក់កណ្តាលចំនួន ១ ៤៩៦នាក់ (ស្រី៤០៧នាក់) និងថ្នាក់រាជធានី-ខេត្តចំនួន ១ ៣៤០នាក់ (ស្រី២៣៥នាក់)

- រៀបចំការបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសសរុបចំនួន ៧៩៤នាក់ (ស្រី២០៥នាក់) ក្នុងនោះ៖
  + ការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លី និងមធ្យមចំនួន ៧៨២នាក់ (ស្រី២០៣នាក់)
  + ការបណ្តុះបណ្តាលក្រៅប្រទេសរយៈពេលខ្លី និងមធ្យមតាមរយៈប្រព័ន្ធអនឡាញ (Online) ចំនួន ៤នាក់។

## ៩ ផ្នែកផែនការ និងស្ថិតិ

- ចូលរួមជួបប្រឹក្សាយោបល់ស្តីពីផលិតភាពកសិកម្មនៅកម្ពុជា បញ្ហាប្រឈម និងទិសដៅគោលនយោបាយ

- ចុះពិនិត្យ និងផ្ទៀងផ្ទាត់សន្និធិស្រូវពូជនៅខេត្តកំពង់ចាម និងខេត្តស្វាយរៀង

- រៀបចំផ្តល់ធាតុចូលសម្រាប់ការរៀបចំរបាយការណ៍វឌ្ឍនភាពវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍របស់ជាតិរយៈពេល៥ឆ្នាំចុងក្រោយ

- រៀបចំពិនិត្យ និងផ្តល់យោបល់ស្តីពី Policy Brief on New Growth Drivers-Request for Review

- ធ្វើការណែនាំ និងធ្វើអង្កេតស្ទង់ទិន្នផលស្រូវប្រាំងឆ្នាំ២០២០-២០២១ ដោយសហការជាមួយមន្ត្រីស្ថិតិថ្នាក់ខេត្តស្រុកនៅខេត្តពោធិ៍សាត់ ក្រចេះ កំពង់ឆ្នាំង និងខេត្តបាត់ដំបង

- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់តាមប្រព័ន្ធ online ជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និងនវានុវត្តន៍ ស្តីពីគោលការណ៍ណែនាំ លើការចុះបញ្ជីអាជីវកម្ម និងការប្រើប្រាស់សេវាក្រោមដំបូលតែមួយផ្តោតលើសហគ្រិនស្ត្រី

- ចុះប្រមូលព័ត៌មានតម្លៃទីផ្សារកសិផលលក់ដុំក្នុងមួយសប្តាហ៍បីដងគឺថ្ងៃចន្ទ ពុធ និងសុក្រ និងតម្លៃលក់រាយរៀងរាល់ថ្ងៃព្រហស្បតិ៍នៃសប្តាហ៍តាមបណ្តាទីផ្សារសំខាន់ៗទីតាំងប្រមូលទិញ និងកន្លែងលក់ដុំផលិតផល នៅតាមបណ្តារាជធានី-ខេត្តទាំង២៥

- បាននិងកំពុងបូកសរុបរបាយការណ៍សមិទ្ធកម្មស្តីពីលទ្ធផលនៃការអនុវត្តថវិកាឆមាសទី១ ឆ្នាំ២០២១ បញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ចុះតាមដាន និងវាយតម្លៃការអនុវត្តសកម្មភាពក្នុងក្របខ័ណ្ឌថវិកាកម្មវិធីនៅខេត្តចំនួន៨ គឺខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង ព្រៃវែង ស្វាយរៀង កំពង់ចាម និងខេត្តត្បូងឃ្មុំ។

## ១០ ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ

- ចុះប្រតិបត្តិការចំណូលក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ(NRMIS) សរុបទឹកប្រាក់ចំនួន ៣ ១៨៤ ៣៧០ ៩៧១រៀល

- បញ្ចេញអាណត្តិបើកប្រាក់ពីក្រសួងសរុបចំនួន ៨ ២០០ ២២៥ ០៦៤រៀល

- រៀបចំសំណើសុំថវិកាចំនួន ២០៤ ៦៧៥,៩៣ដុល្លារអាមេរិក ដើម្បីបំពេញឡើងវិញចូលគណនីគម្រោងរបៀងអភិរក្សជីវចម្រុះមហាអនុតំបន់មេគង្គក្រោមហិរញ្ញប្បទានឥតសំណងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)

- ទទួលថ្លៃសម្បទានដីសេដ្ឋកិច្ចពីក្រុមហ៊ុនចំនួន ២ក្រុមហ៊ុន

- បើកសំណើដេញថ្លៃ និងរៀបចំឯកសារកិច្ចសន្យាស្តីពីការផ្គត់ផ្គង់សម្ភារបរិក្ខារពិសោធន៍ប្រចាំឆ្នាំ២០២១ របស់អគ្គនាយកដ្ឋានកសិកម្ម

- ចូលរួមចុះបិទបញ្ជី បើកគណនេយ្យ ហិរញ្ញវត្ថុទ្រព្យសម្បត្តិរដ្ឋ និងថវិការដ្ឋនៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្ទឹងត្រែង

- ចូលរួមសហការជាមួយអនុគណៈកម្មការដោះស្រាយផលប៉ះពាល់ខេត្តកណ្តាលចុះពិនិត្យ និងវាយតម្លៃលើផលប៉ះពាល់សំណង់ផ្ទះសម្បែង ដីធ្លី ដើមឈើហូបផ្លែ ដំណាំ និងទ្រព្យសម្បត្តិផ្សេងៗរបស់ប្រជាពលរដ្ឋ ដែលអាស្រ័យផលនៅទីតាំងស្ថានីយផ្សព្វផ្សាយ និងស្ថានីព្រៃឈើទួលព្រេច

- ចូលរួមប្រជុំពិភាក្សាស្តីពីការចុះពិនិត្យ និងវាយតម្លៃនូវទីតាំងដីក្រុមហ៊ុនចម្ការកៅស៊ូពាមជាំងចំនួន ១២ហ.ត ស្នើសុំជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់អគ្គនាយកដ្ឋានកៅស៊ូ។

## ១១ ផ្នែកសវនកម្មផ្ទៃក្នុង

- ធ្វើផែនការរដ្ឋទេយ្យបុរេប្រទានសម្រាប់គ្រប់គ្រងឆ្នាំ២០២២
- ធ្វើគម្រោងថវិកាសម្រាប់គ្រប់គ្រងឆ្នាំ២០២២
- ធ្វើគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំ២០២២
- ចុះធ្វើសវនកម្មតាមផែនការសកម្មភាពសវនកម្មផ្ទៃក្នុងឆ្នាំ២០២១ចំនួន ៥អង្គភាពគឺ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ ខេត្តកំពង់ចាម តាកែវ អគ្គនាយកដ្ឋានកសិកម្ម និងគម្រោងការគ្រប់គ្រងធនធានជលផលភូមិភាគឥសាន្ត។

## ១២ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- ចូលរួមកិច្ចប្រជុំតាមប្រព័ន្ធវីដេអូពីចម្ងាយ៣លើក ក្រោមក្របខ័ណ្ឌអាស៊ាន
- បានសម្របសម្រួលកិច្ចប្រជុំចំនួន ៦លើកលើការងារក្នុងប្រទេស
- សម្របសម្រួលកិច្ចការងារជាមួយអង្គការ Heifer ចុះកិច្ចព្រមព្រៀងអនុវត្តគម្រោងលើកកម្ពស់ផលិតផលមាន់ស្រែខ្មែរសម្រាប់មោទកភាពជាតិខ្មែរ
- សម្របសម្រួលកិច្ចការងារជាមួយអង្គការគោសប្បុរសដើម្បីកម្ពុជាចុះកិច្ចព្រមព្រៀងអនុវត្តគម្រោងគោសប្បុរសដើម្បីកម្ពុជា។

## ១៣ ផ្នែកនីតិកម្មកសិកម្ម

### ១៣.១ ការិយាល័យអាជីវកម្មជី-ថ្នាំកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១៦ក្រុមហ៊ុន សរុបចំនួន ១២៧មុខ
- ផ្តល់លិខិតអនុញ្ញាតនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២៧ក្រុមហ៊ុន
- ផ្តល់វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៥ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៧ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំ និងវេចខ្ចប់ជាថ្មីជីកសិកម្មចំនួន ២ក្រុមហ៊ុន។

### ១៣.២ ការិយាល័យមន្ទីរពិសោធន៍

ធ្វើវិភាគរកសារធាតុបន្ទាប់បន្សំ និងលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ៥ក្រុមហ៊ុន សរុបចំនួន ៥០សំណាក។

### ១៣.៣ ការិយាល័យអភិវឌ្ឍបទដ្ឋានគតិយុត្ត

- បានពិនិត្យលើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត និងលិខិតផ្សេងៗចំនួន ២ករណី
- បានពិនិត្យ និងផ្តល់មតិសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត និងលិខិតផ្សេងៗចំនួន ១ករណី។

### ១៣.៤ ការិយាល័យអនុវត្តច្បាប់

- ចុះពិនិត្យការនាំចូលថ្នាំកសិកម្ម និងជីកសិកម្ម និងផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២០ក្រុមហ៊ុន
- ចុះពិនិត្យការស្នើសុំចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្ម និងលាយផ្សំវេចខ្ចប់ជាថ្មីចំនួន ៥ក្រុមហ៊ុន។

## ១៤ ផ្នែកមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

- ធ្វើការតាមដាន និងថែទាំគេហទំព័ររបស់ក្រសួង និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឲ្យដំណើរការល្អរលូន
- តាមដានទិន្នន័យដែលផ្ទុកនៅលើ cloud server នៃគេហទំព័រទាំង៤១
- តាមដានលើការផ្សព្វផ្សាយសកម្មភាពការងាររបស់អង្គភាពថ្នាក់កណ្ដាលលើគេហទំព័រចំនួនផុស៦ព័ត៌មាន
- តាមដាន និងថែទាំម៉ាស៊ីន Firewall ដើម្បីទប់ស្កាត់ការចូលពីអ្នកខាងក្រៅ (Hacker)
- ទទួលសៀវភៅ ឯកសារបច្ចេកទេសកសិកម្ម ទស្សនាវដ្ដីពីនាយកដ្ឋានកិច្ចការរដ្ឋបាល សៀវភៅដែលបណ្ណាល័យកសិកម្មទទួលបាន រួមមានសៀវភៅចូលបណ្ណាល័យតាមរយៈរដ្ឋបាល និងឯកជនសរុបចំនួន ៤ក្បាល
- ការផ្សព្វផ្សាយអំពីបណ្ណាល័យកសិកម្មអេឡិចត្រូនិកមានអ្នកចូលអានចំនួន ៨ ៦៤៩នាក់។

## ១៥ ផ្នែកផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- ចុះទៅថត Video បទយកការណ៍ស្ដីពីការចិញ្ចឹមត្រីអណ្ដែងពូជអាហ្វ្រិករបស់កសិករនៅខេត្តមណ្ឌលគិរី
- ចាក់ផ្សាយឡើងវិញស្ដីពីវេទិកាស្វែងយល់ពីកសិកម្មចំនួន ១ប្រធានបទ
- ចាក់ផ្សាយឡើងវិញស្ដីពីនាទីចុះស្រែជាមួយកសិករចំនួន ២ប្រធានបទ គឺការចិញ្ចឹម និងបង្កាត់បង្កងរបស់កសិករនៅខេត្តតាកែវ និងការដាំដំណាំបន្លែស្ពៃក្ដោបក្នុងផ្ទះសំណាញ់របស់កសិករនៅខេត្តក្រចេះ
- បញ្ជូនអត្ថបទបច្ចេកទេសកសិកម្មដើម្បីចាក់ផ្សាយស្ដីពីបច្ចេកទេសដាំដំណាំត្រកួន បច្ចេកទេសធ្វើផ្សិតចំបើង បច្ចេកទេសដាំដំណាំខាត់ណាផ្កា បច្ចេកទេសចិញ្ចឹមគោជាលក្ខណៈគ្រួសារ សៀវភៅណែនាំស្ដីពីជំងឺអុតក្ដាមគោ ក្របី និងបច្ចេកទេសស្ដីពីការចិញ្ចឹមមាន់ដោយសុវត្ថិភាពពីជំងឺផ្ដាសាយបក្សី
- ជួយដោះស្រាយបញ្ហា និងផ្ដល់ព័ត៌មានបច្ចេកទេសកសិកម្មនានាដល់កសិករ និងអតិថិជនចំនួន ១០សំណួរចម្លើយ គឺរាជធានីភ្នំពេញ ខេត្តកំពង់ធំ កំពង់ឆ្នាំង ស្ទឹងត្រែង កំពត បាត់ដំបង ព្រៃវែង និងខេត្តកំពង់ចាម។

## ១៦ ផ្នែកកសិ-ឧស្សាហកម្ម

- ចូលរួមប្រារព្ធទិវាសហគ្រាសធុនមីក្រូ តូច និងមធ្យម សកល MSME Day តាមប្រព័ន្ធ online
- ចុះស្វែងយល់ពីការអនុវត្តជាក់ស្ដែងស្ដីពីវិញ្ញាបនបត្រសវិញាង្គនៅក្នុងសិប្បកម្មកែច្នៃគ្រាប់ស្វាយចន្ទីជ័យសំបូរ
- ចូលរួមកិច្ចប្រជុំលើកទី១ របស់ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ តាមប្រព័ន្ធ online
- ចូលរួមកិច្ចប្រជុំតាមប្រព័ន្ធ (Zoom Meeting) ស្ដីពីការរៀបចំគោលនយោបាយកសិធុរកិច្ចនៃគម្រោងខ្សែច្រវាក់ផលិតកម្មដោយភាតរៈបរិស្ថាន (CFAVC)
- ចូលរួមកិច្ចប្រជុំ RAI Alliance និងបទបង្ហាញលទ្ធផលនៃការសិក្សាស្រាវជ្រាវស្ដីពីគំរូអាជីវកម្មវិនិយោគវិស័យកសិកម្មប្រកបដោយបរិយាប័ន្ន តាមប្រព័ន្ធ online
- ចូលរួមប្រជុំពិនិត្យ និងពិភាក្សាបន្តលើសេចក្ដីព្រាងច្បាប់ស្ដីពីគុណភាព និងសុវត្ថិភាពចំណីអាហារតាមប្រព័ន្ធ Zoom
- ចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពីការវាយតម្លៃទទួលស្គាល់មន្ទីរពិសោធន៍អនុលោមតាមស្តង់ដារអន្តរជាតិ ISO/IEC 17025:2017 តាមប្រព័ន្ធ Zoom។

## ១៧ ការស្រាវជ្រាវ ការអប់រំ និងការបណ្តុះបណ្តាលកសិកម្ម

### ១៧.១ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់បញ្ចប់លើសេចក្ដីព្រាងឯកសារអភិវឌ្ឍន៍ផែនទីចង្អុលទិសរយៈពេល៥ឆ្នាំរបស់សម្ព័ន្ធកសិកម្មអភិរក្ស និងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា
- ចូលរួមប្រជុំពិនិត្យ និងពិភាក្សាអំពីតួនាទីនិងភារកិច្ចរបស់មន្ទីរពិសោធន៍ជាតិកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមប្រព័ន្ធ Zoom Meeting
- ចុះពិនិត្យមើលការងារនៅស្ថានីយស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកោះកេរ្តិ៍ខេត្តព្រះវិហារ
- ចុះសិក្សាដីកសិកម្មនៅខេត្តព្រះវិហារ

- ចុះធ្វើទិវាស្រែបង្ហាញស្តីពីការប្រើប្រាស់ម៉ាស៊ីនដាំដុះគ្រាប់ស្រូវស្ងួត និងកម្រិតគ្រាប់ដាំដុះនៅខេត្តតាកែវ និងខេត្តព្រៃវែង

- ចុះជ្រើសរើសទីកន្លែងពិសោធន៍នៅខេត្តតាកែវ

- ចុះជ្រើសរើសទីតាំងពិសោធន៍ និងប្រមូលសំណាកដីនៅខេត្តកំពង់ស្ពឺ

- ចុះប្រមូលសំណាកស្មៅសម្រាប់ពិសោធន៍នៅក្នុងវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជានៅខេត្តព្រៃវែង និងខេត្តតាកែវ

- បានចុះត្រួតពិនិត្យការងារពិសោធន៍នៅខេត្តព្រៃវែង និងខេត្តសៀមរាប។

## ១៧.២ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតកំពុងសិក្សាក្នុងឆ្នាំសិក្សា២០២០-២០២១ សរុបចំនួន ៣ ២៥៦នាក់ ចែកចេញជា១០ មហាវិទ្យាល័យ គឺៈ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រជលផល កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី និងមហាវិទ្យាល័យវិទ្យា-សាស្ត្រកៅស៊ូ និងសាលាក្រោយឧត្តម

- ដំណើរការរៀបចំពិធីការពាររបាយការណ៍បញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញារងចំនួន ៣នាក់ ការពារគម្រោងសំណើស្រាវជ្រាវថ្នាក់បណ្ឌិតរបស់និស្សិតចំនួន ១នាក់ និងកម្មវិធីការពារនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ចំនួន ១៣នាក់

- រៀបចំពិធីផ្សព្វផ្សាយអំពីការចាប់ផ្តើមអនុវត្តយុទ្ធសាស្ត្រ១០ឆ្នាំថ្មី២០២១-២០៣០ ជូនដល់ថ្នាក់ដឹកនាំ មន្ត្រីសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងបុគ្គលិកទាំងអស់របស់សាកលវិទ្យាល័យដើម្បីបានយល់ច្បាស់ និងមានវិធានការអនុវត្ត

- រៀបចំប្រជុំពិគ្រោះយោបល់លើលទ្ធផលស្វ័យវាយតម្លៃ និងបច្ចុប្បន្នភាពនៃកម្មវិធីបណ្តុះបណ្តាលថ្នាក់ក្រោយបរិញ្ញាបត្រ វឌ្ឍនភាព បញ្ហាប្រឈម និងយន្តការអភិវឌ្ឍន៍នានាឆ្ពោះទៅការសម្រេច នូវការអនុវត្តយុទ្ធសាស្ត្រ១០ឆ្នាំ

- រៀបចំផែនការ និងប្លង់មេរៀនលើការចិញ្ចឹមមាន់ ការចិញ្ចឹមគោ និងជីវសុវត្ថិភាពដើម្បីបណ្តុះបណ្តាលពីចម្ងាយអនឡាញ ដល់គ្រូនៅវិទ្យាល័យទាំង១៦ក្រោមកិច្ចសហការគម្រោង HEIP SEIP

- ប្រជុំពិភាក្សាស្តីអំពីនីតិវិធីនៃការបែងចែកថវិកាសម្រាប់គណៈកម្មការរៀបចំការរៀបរៀងនិពន្ធ និងកែលម្អសៀវភៅនៅកម្រិតឧត្តមសិក្សា

- ចូលរួមជាវាគ្មិនក្នុងកិច្ចពិភាក្សាស្តីអំពី Safe Production and improved handling of vegetable in Cambodia for the Food Systems Summit 2021។

## ១៧.៣ វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០២០-២០២១ សរុបចំនួន ៨៥១នាក់ (ស្រី៣៣៦នាក់) លើជំនាញៈ កសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិស្វកម្មកសិកម្ម ព្រៃឈើ ជលផល សាកវប្បកម្ម សុរិយោដីនិងការគ្រប់គ្រងដី ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចកសិកម្ម មីក្រូហិរញ្ញវត្ថុ កែច្នៃអាហារ កុំព្យូទ័រ សេដ្ឋកិច្ចនយោបាយនិងស្បៀង និងភាសាអង់គ្លេស

- ចូលរួមសិក្ខាសាលាស្តីពីជីវបម្រុងទន្លេសាបតាមប្រព័ន្ធ Online រៀបចំដោយអង្គការ UNESCO

- ចូលរួមកិច្ចប្រជុំតាមប្រព័ន្ធ Zoom meeting លើការពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការពិសោធន៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន ៥លើក

- បាននិងកំពុងជំរុញការងារស្រាវជ្រាវ និងសហប្រតិបត្តិការជាមួយដៃគូសម្រាប់ការបណ្តុះបណ្តាលគម្រោងសិក្សាស្រាវជ្រាវសំខាន់ៗដែលកំពុងដំណើរការ គឺការពិសោធចិញ្ចឹមគោទឹកដោះ ការពិសោធចិញ្ចឹមបង្គា ការពិសោធបង្កាត់ពូជមាន់ ការសិក្សាពិសោធថ្នាំបណ្តេញសត្វល្អិត ការពិសោធចិញ្ចឹមពពែនៅតំបន់ភ្នំ ការសិក្សាស្រាវជ្រាវបង្កាត់កេសរកូល ការពិសោធដំណាំព្រីង ការសិក្សាពិសោធផលិតម្សៅឫស្សី ការបណ្តុះជាលិការុក្ខជាតិ ការពិសោធចិញ្ចឹមកង្កែប សាងសង់កសិដ្ឋានវារីសត្វ-រុក្ខជាតិ ការពិសោធចិញ្ចឹមត្រីបបែលនិងត្រីលម្អផ្សេងៗ ការសិក្សាផលិតកម្ម និងច្រវាក់តម្លៃស្វាយចន្ទី។

## ១៧.៤ វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០២០-២០២១ សរុបចំនួន ៦១០នាក់ (ស្រី២៧៤នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម ក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- ពិសោធន៍លើជីសរីរាង្គពីការលូតលាស់ដំណាំបន្លែស្ពៃក្រញាញ់
- ពិសោធន៍តាមដានការបំផ្លាញរបស់កត្តាចង្រៃលើដំណាំខាត់ណាផ្កា
- ពិសោធន៍ដំណាំលើទឹកដោយប្រើប្រាស់ប្រភពទឹកពីអាងចិញ្ចឹមត្រីនៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម
- បានធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហមនៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម
- បានធ្វើការសាកល្បងចម្រាញ់ប្រេងស្វាយចន្ទីសម្រាប់ផលិតជាគ្រឿងក្រអូប
- បានចូលរួមបណ្តុះបណ្តាលកសិករជាមួយដៃគូរបស់ក្រុមហ៊ុន និងធ្វើការស្រាវជ្រាវរួមគ្នាអំពីការកែច្នៃកសិផលលើដំណាំស្វាយចន្ទី ល្ហុង ល្ពៅ ក្រូចថ្លុង ស្លឹកគ្រៃ និងម្រេច។

**១៧.៥ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

- ត្រួតពិនិត្យទូទៅ ការការពារ និងថែទាំចម្ការពិសោធន៍ក្លូន កូនកៅស៊ូស៊ីដលីង និងច្បារបង្កាត់ពូជ
- ស្រង់ទិន្នន័យ បញ្ចូល និងវិភាគទិន្នន័យចម្ការពិសោធន៍ក្លូន(ទិន្នផលជ័រ) សរុបចំនួន ១២ចម្ការពិសោធន៍
- ត្រួតពិនិត្យការចៀរជ័រ ការសាប្រមូលផលទឹកជ័រ និងស្រង់ទិន្នន័យជ័រកៅស៊ូតាមពិធីសារពិសោធន៍គ្រប់ចម្ការពិសោធន៍
- រៀបចំលាយថ្នាំរំញោច Ethephon តាមកំហាប់ខុសៗគ្នាដើម្បីលាបរំញោចតាមពិធីសារពិសោធន៍
- វាស់ទំហំដើមចម្ការពិសោធន៍ឥទ្ធិពលនៃការបើកមុខចៀរនៅទំហំដើមខុសៗគ្នា
- ថែទាំថ្នាលបណ្តុះកូនកៅស៊ូឆ្នាំ២០២០-២០២១ (បាញ់ថ្នាំ Dithan M45 ការពារនិងព្យាបាលជំងឺស្លឹក)
- ដាំដុះកូនកៅស៊ូឆ្នាំ២០២១ ក្លូនRRIM600 លើផ្ទៃដី៩,៥ហ.ត
- ត្រួតពិនិត្យការប្រមូលផលជ័រកៅស៊ូ និងការកែច្នៃកៅស៊ូសន្លឹកនៅក្នុងរោងចក្រ
- ត្រួតពិនិត្យសម្ភារ និងឧបករណ៍មន្ទីរពិសោធន៍ជាតិយថាប្រភេទ
- វិភាគកៅស៊ូ RSS ចំនួន ៦សំណាកដើម្បីវាយតម្លៃគុណភាពនៃការកែច្នៃ។

## III-សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាសម្រេចបាន ២ ៤៤៦ ២៨៦ហ.ត ស្មើនឹង៩៣,៧៦% នៃផែនការចំនួន ២ ៦០៩ ០៦៥ហ.ត និងការប្រមូលផលស្រូវស្រាលចំនួន ១២១ ៩៥៣ហ.ត ដោយទទួលបរិមាណផលសរុបចំនួន ៤៩៨ ២៩៩តោន លើសឆ្នាំមុនចំនួន ២៣០ ៦០៣តោន និងទទួលបានទិន្នផលគិតជាមធ្យម ៤,០៨៦តោន/ហ.ត។ ក្រសួងបានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការស្តារការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសត្វល្អិតចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ការជំរុញឱ្យចុះត្រួតពិនិត្យ និងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វឈើក្នុងតំបន់ផ្ទុះជំងឺ បទល្មើសព្រៃឈើ និងបទល្មើសជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រងការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងបានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រឱ្យសម្រេចបាននូវលទ្ធផលល្អប្រសើរតាមផ្នែកនីមួយៗស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម។

## IV- ទិសដៅអនុវត្តបន្ត

**១ ផ្នែកដាំដុះ**

- បន្តវិធានការជំរុញការងារបង្កបង្កើនផលកសិកម្មរដូវវស្សាឆ្នាំ២០២១

- បន្តធ្វើការជំរុញផលិតកម្មស្បៀងសម្រាប់ឆ្លើយតបទៅនឹងហានិភ័យនៃការឆ្លងរាលដាលជំងឺកូវីដ-១៩

- បន្តជំរុញការនាំចេញផលិតផលកសិកម្មទៅកាន់ទីផ្សារអន្តរជាតិពិសេសប្រទេសចិន

- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណ និងគុណភាពតាមផែនការកំណត់ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង

- បន្តជំរុញ និងបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស និងកសិករអំពីបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម និងបន្តការសិក្សាស្រាវជ្រាវបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម ការងារផលិតពូជ និងបន្សុទ្ធពូជនៅកសិដ្ឋាន និងស្ថានីយ

- ត្រៀមលក្ខណៈមានដូចជាៈ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់នឹងជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្ម

- បន្តអង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡត់ពិសោធន៍កូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ។

## ២ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗ ចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង

- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- បន្តពង្រឹង និងផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមសត្វដល់កសិករ

- ចុះពិនិត្យអនាម័យសត្តឃាតដ្ឋាន ផ្សព្វផ្សាយអំពីលក្ខណៈ និងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ ជំងឺឆ្លង(ជំងឺចុងអង្គរ របេងជ្រូក គោ) បន្តតាមដានស្ថានភាពជំងឺស៊ូណូស និងវិធានការទប់ស្កាត់នៅតាមរាជធានី-ខេត្ត

- ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យ កន្លែងផ្ទុះជំងឺ និងកន្លែងដែលរាលដាលជំងឺផ្តាសាយបក្សី (H5N1) និងជំងឺ A(H1N1)

- ជំរុញការអនុវត្តកម្មវិធីផ្សព្វផ្សាយលើកកម្ពស់ការអប់រំយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការប្រើប្រាស់ចំណីសត្វ និងបសុឱសថដល់អាជីវករ និងអ្នកប្រើប្រាស់

- បន្តចុះវាយតម្លៃកសិដ្ឋានចិញ្ចឹមសត្វស្របតាមបច្ចេកទេស និងគោលការណ៍អនុវត្តការចិញ្ចឹមសត្វល្អ តាមខេត្តគោលដៅ

- បន្តរៀបចំឯកសារស្តីពីអត្ថប្រយោជន៍នៃការគ្រប់គ្រងកាកសំណល់សត្វ។

## ៣ ផ្នែកព្រៃឈើ

- ខិតខំបន្តត្រួតពិនិត្យ តាមដាន និងពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្មឈើ រោងចក្រ សិប្បកម្មកែច្នៃ និងអាជីវកម្មឈើឲ្យបានហ្មត់ចត់ ព្រមទាំងចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំចេញឈើ និងផលិតផលកែច្នៃឈើគ្រប់ប្រភេទដែលគ្មានការអនុញ្ញាតដើម្បីលុបបំបាត់សកម្មភាពដឹកជញ្ជូនឈើខុសច្បាប់ឲ្យមានប្រសិទ្ធភាពខ្ពស់

- បន្តពង្រឹង និងពង្រីកសហគមន៍ព្រៃឈើចូលរួមគ្រប់គ្រងថែរក្សាធនធានព្រៃឈើ តាមដានត្រួតពិនិត្យ ការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ឱ្យបានល្អ ព្រមទាំងបណ្តុះផ្នត់គំនិតបង្កើតមុខរបរថ្មីៗបន្ថែមទៀត ដើម្បីបង្កើនចំណូលតាមរយៈប្រព័ន្ធកសិ-រុក្ខកម្ម ការចិញ្ចឹមសត្វ សំដៅកាត់បន្ថយការពឹងអាស្រ័យលើផល និងអនុផលព្រៃឈើ ជាពិសេសខិតខំជំរុញការផ្សព្វផ្សាយ អប់រំ បណ្តុះបណ្តាល បំពាក់បំប៉នដល់សហគមន៍មូលដ្ឋានយល់ដឹងពីផលប្រយោជន៍ព្រៃឈើ

- បន្តផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បទប្បញ្ញត្តិ បទបញ្ជា លិខិតបទដ្ឋានគតិយុត្ត ជាពិសេសសេចក្តីជូនដំណឹងលេខ១៣៤៨ សជណ.កជ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីឱ្យបានជ្រួតជ្រាបដល់មូលដ្ឋានភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង រាជធានី-ខេត្តទូទាំងប្រទេស ព្រមទាំងមានចំណាត់ការផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ និងមានប្រសិទ្ធភាពខ្ពស់ពាក់ព័ន្ធនឹងការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីវាតយកដីធ្វើកម្មសិទ្ធិ

- បន្តជំរុញការដាំដុះស្តារព្រៃឈើឡើងវិញដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសម្រាប់ចែកចាយជូនប្រជាពលរដ្ឋ។

## ៤ ផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- ជំរុញសង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផល បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីជលផលឱ្យបានតឹងរ៉ឹងបំផុត

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"។

## ៥ ផ្នែកពាក់ព័ន្ធផ្សេងៗ

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់ជី-ថ្នាំកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់ជី-ថ្នាំកសិកម្ម ដើម្បីសុខភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលសម្រាប់បង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្តែង រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា អភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាឱ្យមានផលិតភាពខ្ពស់ដោយគិតគូរទៅលើការប្រែប្រួលអាកាសធាតុ និងស្តង់ដារ។៚

ថ្ងៃ ច័ន្ទ ១កើត ៨ ខែ ភទ្របទ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**